


## ប្រភពដើម

អង្គការសម្រេចសុបិនកុមារបានបង្កើតឡើងជាផ្លូវការនៅប្រទេសស្វីសនាឆ្នាំ ២០០៣ ដោយមានប្រណិធាន និង ការខិតខំប្រឹងប្រែងក្នុងការជួយដល់កុមារ និង យុវជនដែលគ្មានឱកាសនៅក្នុងប្រទេសអនុតំបន់ទន្លេមេគង្គដែលជាមូលដ្ឋានកណ្តាលនៃការកើតមានឡើងនូវវិបត្តិផ្នែកមនុស្សធម៌, ការអប់រំ, គុណភាពជីវិត និង បរិស្ថាន ជាពិសេសក្នុងចំណោមកុមារ និង យុវជនដែលជាអ្នកទទួលផលប៉ះពាល់ច្រើនជាងគេ។ អង្គការនេះបានចុះបញ្ជីជាផ្លូវការក្នុងប្រទេសថៃទៅជាមូលនិធិសម្រេចសុបិនកុមារនៅឆ្នាំ ២០០៥។

## ស្ថានភាពការណ៍ក្នុងប្រទេសអនុតំបន់ទន្លេមេគង្គ

បញ្ហាសេដ្ឋកិច្ច និង លំហក្នុងសង្គមដែលមិនស្មើគ្នា

បញ្ហាការមិនទទួលស្គាល់ និង មិនយល់ដឹងអំពីភាពខុសគ្នារបស់ពូជសាសន៍

បញ្ហាគ្មានតម្លាភាពក្នុងការអនុវត្តន៍ និង ការយកចិត្តទុកដាក់ថែទាំ

បញ្ហាកង្វះប្រព័ន្ធរៀបចំផ្នែកសេដ្ឋកិច្ចឱ្យបានល្អ

បញ្ហាសង្គ្រាមក្នុងប្រទេស និង អស្ថេរភាពផ្នែកនយោបាយ

⇒

កុមារជាអ្នកទទួលផលប៉ះពាល់ពីការ បំពានសិទ្ធ និង ភាពអយុត្តិធម៌

បង្កឱ្យមានអ្នកគ្មានសញ្ជាតិ និង ខ្វះការទទួលស្គាល់ស្ថានភាពរបស់បុគ្គលក្នុងសង្គម

គ្មានឱកាសទទួលបានការអប់រំ និង សេវាសុខភាព

ត្រូវទទួលការបង្ខិតបង្ខំឱ្យចាកចេញពីលំនៅស្ថាន និង ក្លាយទៅជាជនភៀសខ្លួនដែលគ្មានស្ថានភាពរស់នៅក្នុងសង្គម

⇓

កុមារទាំងនេះត្រូវការជំនួយផ្ទាល់ ដូចជាកុមារតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារពលកម្ម និង កុមារដែលទទួលនូវភាពអយុត្តិធម៌ផ្នែកផ្លូវច្បាប់ និងធ្លាក់ខ្លួនទៅជាអ្នកគ្មានស្ថានភាពនៅក្នុងសង្គម

**ប្រទេសថៃ** : មានកុមារជាង ១ លាននាក់ ដែលត្រូវការជំនួយសំរាប់ការការពារភាពជាមនុស្ស ពួកគេគឺជាកុមារកំព្រា កុមារនៅតាមចិញ្ចើមថ្នល់ កុមារធ្វើពលកម្ម ។ល។ ទន្ទឹមគ្នានេះក៏នៅមានកុមារជាច្រើនទៀតដែលមិនទាន់ទទួលបានការអប់រំមូលដ្ឋាន។

**ប្រទេសកម្ពុជា** : មានកុមារតិចជាង ៥០% នៃកុមារទូទាំងប្រទេសដែលទទួលបានការអប់រំបឋមសិក្សា និង ប្រហែល ៤៥% កំពុងជួបនឹងបញ្ហាការហូបចុកមិនគ្រប់គ្រាន់។

**ប្រទេសភូមា** : ១ នៃ ១០ ភាគរបស់កុមារដែលទើបកើតនៅក្នុងប្រទេសភូមាបានបាត់បង់ជីវិតក្នុងវ័យទារក។ ប្រហែល ៣០% នៃកុមារទាំងអស់ដែលរស់នៅក្នុងតំបន់សង្គ្រាមរបស់ប្រទេសនេះបានបាត់បង់ជីវិតមុនអាយុ ៥ ឆ្នាំ។

**ប្រទេសឡាវ** : ២០% នៃភូមិទាំងអស់ក្នុងប្រទេសឡាវមិនទាន់មានសាលារៀន។ មានតែ ១៥% នៃប្រជាជនទាំងអស់ដែលទទួលបានការអប់រំបឋមសិក្សា និង ៥% ដែលបានចូលរៀននៅមធ្យមសិក្សា។

## វិធីដំណើរការ

ជួយជំរុញសហគមន៍ដែលគ្មានឱកាសក្នុងប្រទេសអនុតំបន់ទន្លេមេគង្គ ដើម្បីលើកកំពស់គុណភាពជីវិតដោយមូលនិធិនឹងធ្វើការជាមួយសហគមន៍ក្នុងការអភិវឌ្ឍន៍ផ្នែកសុខភាព និង ផ្តល់ឱកាសលើវិស័យអប់រំជូនដល់កុមារ ព្រមទាំងបណ្តុះជំនាញផ្នែកអាជីពដើម្បីគ្រួសាររបស់គេ។

Child's Dream Akphiwat Khmer
#040, National Road No. 6
Salakansaeng Village, Svay Dang Kum Commune
Siem Reap, Cambodia

"ឱ្យត្រីខ្ញុំមួយក្បាល ខ្ញុំមានហូបមួយថ្ងៃ បង្រៀនខ្ញុំឱ្យចេះរកត្រី ខ្ញុំមានហូបជារៀងរហូត" ទោះជាយ៉ាងនេះក៏ដោយការជួយឱ្យសម្រេចបាននូវការអភិវឌ្ឍន៍មិនមែនស្ថិតនៅលើការឱ្យត្រី ឬ បង្រៀនឱ្យចេះរកត្រីតែមួយមុខនោះទេ ប៉ុន្តែត្រូវយល់ដល់ពួកគេថា តើចាំបាច់ត្រូវមានត្រីឬទេ? ។ គោលសំខាន់ដែលនឹងនាំឱ្យមានស្ថេរភាពនៃការអភិវឌ្ឍន៍នោះវាស្ថិតនៅលើការយកចិត្តទុកដាក់ស្តាប់ និង យល់អំពីការចាំបាច់របស់សហគមន៍ដោយយើងប្រើវិធីការអភិវឌ្ឍន៍របៀបពីក្រោមឡើងលើ ដែលយើងផ្តោតទៅ លើការចាំបាច់របស់សហគមន៍ជាគោល ។

ក្រោយពីយើងបានយល់ដឹង និង មានសម្ព័ន្ធភាពល្អជាមួយសហគមន៍ហើយ យើងនឹងចាប់ផ្តើមផ្តល់ជំនួយទៅតាមការចាំបាច់ជាមូលដ្ឋានរបស់កុមារជាមុន បន្ទាប់ទៅទៀតយើងនឹងពិនិត្យមើលនៅការអភិវឌ្ឍន៏វិស័យផ្សេងៗដែលអាចធ្វើទៅបានដោយឈរទៅលើការចាំបាច់របស់សហគមន៍ដូចគ្នា ។

## តើអង្គការសម្រេចសុបិនកុមារធ្វើអ្វីខ្លះ?

ការធ្វើការរបស់អង្គការបានបែងចែកការងារជា ៣ ផ្នែកគឺ ផ្នែកសុខភាព ផ្នែកអប់រំមូលដ្ឋាន និង ផ្នែកអប់រំក៏រិតឧត្តមសិក្សា ឬ ជាន់ខ្ពស់ ។

**ផ្នែកសុខភាព** : ដើម្បីកាត់បន្ថយអត្រាស្លាប់របស់កុមារ និង ជំរុញឱ្យកុមារទទួលបានសេវាសុខភាព ។

**ផ្នែកអប់រំមូលដ្ឋាន** : ដើម្បីពង្រីកឱកាសដល់ការអប់រំមូលដ្ឋាន និង កាត់បន្ថយអត្រាប្រថុយប្រថានក្នុងការធ្លាក់ខ្លួនចូលក្នុងភាពអយុត្តិធម៌ ។

**ផ្នែកអប់រំក៏រិតឧត្តមសិក្សា** : ដើម្បីអភិវឌ្ឍន៍អាជីពឱ្យបានទូលំទូលាយ និង ផ្តល់ឱកាសឱ្យមានប្រាក់ចំណូល ព្រមទាំងផ្ទេរចំណេះ ជំនាញផ្សេងៗដែលចាំបាច់ និង ស្របទៅតាមតំរូវការទីផ្សារ ។




មានកុមារជាង ៤០,០០០ នាក់ ក្នុងប្រទេសភូមាបានទទួលជំនួយក្នុងគំរោងការពារជម្ងឺគ្រុនចាញ់ ដោយការផ្តល់ចំណេះដឹង ការព្យាបាលប្រកបទៅដោយសម្ភារៈ និង ថ្នាំសង្កូវគ្រប់គ្រាន់ ។ កុមារច្រើនជាង ៥០,០០០ នាក់ ក្នុងប្រទេសភូមាដែលមានអាយុមិនលើស ១២ ឆ្នាំ បានទទួលវីតាមីន A និង ថ្នាំបញ្ចុះព្រូន ។ កុមារច្រើនជាង ៥៨,០០០ នាក់ ក្នុងប្រទេសភូមាដែលមានអាយុតិចជាង ១៤ ឆ្នាំ បានទទួលវ៉ាក់សាំងការពារជម្ងឺ និង កុមារច្រើនជាង ៤០,០០០ នាក់ បានទទួលការតាមដានថែរក្សាសុខភាពអនាម័យពីអ្នកស្ម័គ្រចិត្តរបស់យើងដែលមានចំនួនដល់ទៅ ២០០ នាក់ ។ កុមារ ៥៦៦ នាក់ ទទួលបានជំនួយក្នុងការវះកាត់សង្គ្រោះជីវិត ។

សិស្សជាង ៣០,០០០ នាក់ បានទទួលជំនួយសម្ភារៈរៀន ព្រមទាំងការផ្គត់ផ្គង់សម្ភារៈកីឡា។ លោកគ្រូ-អ្នកគ្រូជាង ២,០០០ នាក់ ទទួលបានឧបករណ៍ និង សម្ភារៈបង្រៀន។ យើងបានសាងសង់មណ្ឌលកុមារច្រើនជាង ៥០ កន្លែង និង បានទំនុកបំរុងសិស្សថ្នាក់បឋមសិក្សា និង មធ្យមសិក្សាប្រហែល ១០,០០០ នាក់ និង យើងមានគំរោងសាងសង់អន្តេវាសិកដ្ឋានចំនួន ១០ កន្លែង សំរាប់ជាទីស្នាក់នៅរបស់សិស្សចំនួន ៦០០ នាក់។

និស្សិតចំនួន ៧២ នាក់ ដែលបានទទួលអាហារូបករណ៍ពីយើងកំពុងសិក្សានៅប្រទេសថៃ និង ហុងកុង។ យើងបានឧបត្ថម្ភសិស្សដែលរៀនពូកែចំនួន ៣៨០ នាក់ អោយសិក្សានៅសាលាក្រោមឧត្តមសិក្សាចំនួន ៣ កន្លែង។ មានសិស្សចំនួន ២០ នាក់ ដែលទទួលបានឱកាសត្រៀមលក្ខណៈចូលរៀនបន្តនៅកំរិតទុតិយភូមិ។ មានសិស្សចំនួន ៦០ នាក់ កំពុងទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង មានសិស្សចំនួន ២០ នាក់ កំពុងធ្វើកម្មសិក្សាជាមួយក្រុមហ៊ុនផ្សេងៗ។

**តើលោក-អ្នកអាចជួយយើងបានដោយរបៀបណា?**

លោក-អ្នកជាមនុស្សម្នាក់ដែលអាចជួយឱ្យសុបិនរបស់កុមារក្លាយទៅជាការពិតបាន ដោយការជួយបរិច្ចាគជាថវិកាដើម្បីគាំទ្រដល់ការអនុវត្តន៍កម្មវិធីរបស់អង្គការសម្រេចសុបិនកុមារ។ ថវិកាដែលទទួលបានពីការបរិច្ចាគទាំងអស់នឹងយកទៅប្រើប្រាស់ឱ្យមានប្រយោជន៏ខ្ពស់បំផុតដល់កុមារក្នុងគម្រោងរបស់យើង នេះជាការតាំងចិត្តដ៏ស្មោះស្ម័គ្ររបស់យើងក្នុងការអនុវត្តន៏ការងារនេះ។ ការបរិច្ចាគថវិកាអាចធ្វើបានច្រើនវិធី : បរិច្ចាគជាថវិកាដល់ដៃ តាមរយៈបញ្ជីធនាគារ ក្រេឌីតកាត សែក និង Paypal។ ចំពោះប្រទេសស្វីស សហរដ្ឋអាមេរិក អូស្ត្រាលី ហុងកុង និង ប្រទេសនីហ្សីឡែន ត្រូវបានផ្តល់សិទ្ធយកទៅបន្ថយពន្ធបាន។

សូមមេត្តាបើកមើលវិធីបរិច្ចាគ និង វិធីកាត់បន្ថយពន្ធនៅក្នុងគេហទំព័ររបស់យើង **www.childsdream.org**។